តមកពីទំព័រ ក8

# មន្ត្រីរដ្ឋាភិបាល...

យ៉ាន់ ទីមាណូរ៉ុង មន្ត្រីគម្រោង ដែលជា គណៈប្រតិភូនៃសហភាពអឺរ៉ុបប្រចាំ ប្រទេសឥណ្ឌូណេស៊ី និងព្រុយណេ ដារូសាឡាំ ។

គណៈប្រតិភូកម្ពុជាចូលរួមក្នុង សន្និសីទនេះមាន១៣ រូបមកពីក្រសួង មហាផ្ទៃ អភិបាលក្រុងកំពត អភិបាលរង ខេត្តបាត់ដំបង មន្ត្រីសម្ព័ន្ធភាពជាតិ ឃុំសង្កាត់ មន្ត្រីជំនាញអង្គការខុនរាដ និងអ្នកសារព័ត៌មានរស្មីកម្ពុជា ។

ដៃគូអនុវត្តគម្រោងរួមមាន សមាគមនៃទីក្រុងវៀតណាម (ACVN) មូលនិធិអភិវឌ្ឍន៍ រដ្ឋាភិបាលមូលដ្ឋាន នៃប្រទេសហ្វីលីពីន(LOGODEF) សម្ព័ន្ធ ភាពជាតិឃុំ សង្កាត់ នៃប្រទេសកម្ពុជា (NLC/S) វិទ្យាស្ថានបរិស្ថាននៃប្រទេស ថៃ (TEI) សហព័ន្ធទីក្រុងនិងរដ្ឋា- ភិបាលមូលដ្ឋាននៅអាស៊ីប៉ាស៊ីហ្វិក (UCLG ASPAC) ។

ថ្លែងក្នុងពិធីបើកនាថ្ងៃទី ២៧ កញ្ញា លោកស្រី ស៊ូហ្សាន ស្តេហ្វាន នាយកគម្រោង DELGOSEA បានមាន ប្រសាសន៍ថា ភាពជាដៃគូសម្រាប់ អភិបាលកិច្ចមូលដ្ឋានតាមបែបប្រជាធិប- តេយ្យនៅអាស៊ីអាគ្នេយ៍គឺជាបណ្តាញ នៃសមាគមរដ្ឋាភិបាលមូលដ្ឋាន រដ្ឋ- អំណាចមូលដ្ឋាន អង្គការមិនមែន រដ្ឋាភិបាល និងវិទ្យាស្ថានអប់រំនានាក្នុង ប្រទេសកម្ពុជា ឥណ្ឌូណេស៊ី ហ្វីលីពីន ថៃឡង់ដ៍ និងវៀតណាម ។

គោលបំណងនៃគម្រោងនេះ គឺ ចូលរួមធ្វើឱ្យប្រសើរឡើងនូវស្ថានភាព រស់នៅនៃក្រុមជនទន់ខ្សោយក្នុងអាស៊ី- អាគ្នេយ៍តាមរយៈការជំរុញនូវការចូល រួមរបស់ក្រុមទាំងនោះទៅក្នុងដំណើរ ការធ្វើផែនការ និងការសម្រេចចិត្តនៅ មូលដ្ឋាន។ ធ្វើឱ្យប្រសើរឡើងនូវចំណេះ ដឹងឥរិយាបទ និងការអនុវត្តន៍នានា របស់សមាគម រដ្ឋាភិបាលមូលដ្ឋានក្នុង ការសម្របសម្រួលការផ្ទេរ និងអនុវត្ត តាមនៃការអនុវត្តន៍ល្អនានា ។ បង្កើត បណ្តាញអាផ្ទាធរ និងសមាគម រដ្ឋា- ភិបាលមូលដ្ឋាន អង្គការមិនមែនរដ្ឋា- ភិបាល និងវិទ្យាស្ថានអប់រំនានា ដើម្បី ធ្វើការផ្លាស់ប្តូរនិងផ្ទេរការអនុវត្តន៍ល្អ ស្តីពីអភិបាលកិច្ចមូលដ្ឋានតាមបែប ប្រជាធិបតេយ្យនៅក្នុងតំបន់ ។

លោកស្រី ស៊ូហ្សាន ជឿជាក់ថា ការ ចូលរួមរបស់ប្រជាពលរដ្ឋជាផ្នែកស្នូល នៃយុទ្ធសាស្ត្រអភិវឌ្ឍន៍រដ្ឋបាលមូល- ដ្ឋាន ។ បញ្ហានានាដែលជួបប្រទះដោយ ក្រុមប្រជាពលរដ្ឋទន់ខ្សោយមានជា- អាទិ៍ ភាពក្រីក្រ ការទទួលបានសេវា- សាធារណៈ ព័ត៌មាន និងសុខុមាលភាព ផ្នែកសេដ្ឋកិច្ចនឹងត្រូវដោះស្រាយបាន ល្អប្រសើរប្រសិនបើរដ្ឋាភិបាលមូលដ្ឋាន និងសមាជិកសហគមន៍របស់ខ្លួនចូលរួម ក្នុងកិច្ចប្រឹក្សាយោបល់ជជែកវែកញែក និងធ្វើសេចក្តីសម្រេចចិត្តជាមួយគ្នា។ ធ្វើ ឱ្យប្រសើរឡើងនៃអភិបាលកិច្ចស្ថាប័ន បរិស្ថានទីប្រជុំជន ការលើកស្ទួយការ វិនិយោគ និងសារពើពន្ធ ។ក្នុងពេល ដែលយើងជំរុញឱ្យមានការចែករំលែក មេរៀនពីគ្នាទៅវិញទៅមក ដើម្បីធ្វើឱ្យ ប្រសើរឡើងនៃគុណភាពសេវាសាធា- រណៈរបស់រដ្ឋាភិបាលមូលដ្ឋាន យើង ក៏ទទួលស្គាល់នូវស្ថានភាពខុសគ្នានៃ វប្បធម៌សង្គម និងនយោបាយផងដែរ។ ភាពខុសគ្នាទាំងនេះក៏ជាមាគ៌ាមួយ ដើម្បីសម្រេចបាននូវការអនុវត្តន៍មាន ចីរភាពក្នុងបរិបទវិមជ្ឈការ ។

កិច្ចប្រជុំនេះត្រូវបានចែកចេញ ជាពីរវគ្គក្នុងនោះវគ្គទីមួយគឺ ការពិនិត្យ សមាជពាក់កណ្តាលត្រីមាសទាំងមូល- ឡើងវិញ ការវាយតម្លៃ និងមេរៀន បទពិសោធន៍ ហើយវគ្គទីពីរ នឹងត្រូវ ពិនិត្យមើលលើបញ្ហានិរន្តរភាព- គម្រោង។ កម្មវិធីនេះនឹងមានបញ្ចូល វគ្គស្តីពី Market Place ដែលជាវគ្គមួយ តម្រូវឱ្យទីក្រុងសាកល្បងទាំង១៦ បង្ហាញពីគម្រោងរបស់ខ្លួន ក៏ដូចជា- ការបើកឱកាសឱ្យអ្នកសារព័ ការសាកសួរ និងការពិភាក ស្តីពីការប្រមើលមើលយ៉ាង បញ្ហាប្រឈមនានា នៅក្នុងដំ នៃការអនុវត្តន៍នូវអភិបាលកិ ដ្ឋានដែលមានរួចជាស្រេច ក្រុងសាមីនីមួយៗ។ សមាគម ជាច្រើនដែលមកពីបណ្តាប្រ ដៃគូទាំង៥ និងអ្នកពាក់ព័ន្ធសំ ដំណើរការអនុវត្តន៍ក៏នឹងត្រូ បញ្ចេញទស្សនៈ និងគំនិត ស្តីពីវឌ្ឍនភាពនៃការងាររប ពេលកន្លងមកផងដែរ។មន្ត្រី ដែលត្រូវបាន អញ្ជើញមក នឹងធ្វើការបង្ហាញពីផែនការ និងគំនិតផ្តួចផ្តើម ដើម្បីធ្វើឱ្យ ប្រសើរឡើងលើការងារអភិ មូលដ្ឋាន ហើយស្របពេលគ្នា ផ្តល់នូវអនុសាសន៍ដំបូងលើ អនុសាសន៍ស្តីពីគោលនយោប គម្រោង DELGOSEA ។

ការផ្សេងផ្ទាត់ដ៏សមស្រ បទពិសោធន៍ការងារកន្លងមកនិង ខ្លួនសម្រាប់ពេលអនាគត នឹង ឃើញពីលទ្ធផលនៃការវាយត កណ្តាលគម្រោងនិងការផ្តល់សំ ដើម្បីអនុវត្តបន្ត ដោយផ្អែក ពិសោធន៍ ដែលបានអនុវត្តកន្ល

លោក ភីធ័រខូភីងហ្វ័ គម្រោងនៅ KAS បានមាន ប្រ ថា "នេះគឺជាពេលវេលាដែល រំភើបមួយ នៅក្នុងជីវិតនៃ DELGOSEA ។ កិច្ចប្រជុំនេះ ឱកាសដ៏វិសេសវិសាល ដើម្បី ជួបជុំគ្នានិងទទួលយកបទពិ ព្រមទាំងមើលពីអ្វីដែលនឹង បន្ទាប់ទៀត ក៏ដូចជាវិធីសា យើងអាចឈានទៅរកនិរន្តរ ការងារអភិបាលកិច្ចល្អមូលដ្ឋាន គម្រោងត្រូវបានបញ្ចប់ ៕



*លោកនាក់ សុវណ្ណារី អភិបាលក្រុងកំពត ធ្វើបទបង្ហាញ- នៅក្នុងសន្និសីទថ្នាក់ប្រទេស នៃគម្រោង DELGOSEA នាទីក្រុងបាតាំ ប្រទេសឥណ្ឌូណេស៊ី កាលពីថ្ងៃ២៨ កញ្ញា ឆ្នាំ២០១១ (រូបថត:សុផល)*



*លោកស្រីស៊ូហ្សាន ស្តេហ្វាន នាយកគម្រោង DELGOSEA ថ្លែងក្នុងសន្និសីទសារព័ត៌មាន មុនពេលកិច្ចប្រជុំស្តីពីគម្រោង- ភាពជាដៃគូ សម្រាប់អភិបាលកិច្ចមូលដ្ឋាន តាមបែប- លិទ្ធិប្រជាធិបតេយ្យ នៅអាស៊ី-អាគ្នេយ៍ (រូបថត:សុផល)*